**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក ស ក**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

គណៈកម្មាធិការលទ្ធកម្ម

លេខ : ...០៦...../២៥ គល

## សេចក្តីជូនដំណឹង

**ស្តីពីការអញ្ជើញចូលរួមដេញថ្លៃការថែទាំ ជួសជុលសម្ភារបរិក្ខារ ឧបករណ៍បច្ចេកទេស និងតបបណ្តាញ ប្រចាំឆ្នាំ២០២៥ របស់អង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សូមជូនដំណឹងដល់បណ្តា ក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាស ឯកត្តបុគ្គល) ទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជា ដែលប្រកបអាជីវកម្មផ្នែកសេវាកម្មពាក់ព័ន្ធនិងការថែទាំ ជួសជុលសម្ភារបរិក្ខារ ឧបករណ៍បច្ចេកទេស និងតបណ្តាញ ឱ្យបានជ្រាបថា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងដាក់ឱ្យដេញថ្លៃជាសាធារណៈ ដើម្បីជ្រើសរើសអ្នកទទួលការអនុវត្តការថែទាំ ជួសជុលសម្ភារបរិក្ខារ ឧបករណ៍បច្ចេកទេស និងតបណ្តាញ ប្រចាំឆ្នាំ២០២៥ ជូនអង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលដេញថ្លៃ និងមានដាក់លក់នៅអង្គភាពលទ្ធកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលមានអាសយដ្ឋានលេខ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ចាប់ពីថ្ងៃទី..០៣......ខែ..កក្កដា..ឆ្នាំ២០២៥ នេះតទៅរៀងរាល់ម៉ោងធ្វើការ( ទូរស័ព្ទទាក់ទងលេខ០៦០ ២១ ២១ ៨៣)។

ឯកសារដេញថ្លៃដែលបានបំពេញរួច ត្រូវប្រគល់ជូនអង្គភាពលទ្ធកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ យ៉ាងយូរបំផុតត្រឹមថ្ងៃទី....៦..........ខែ..សីហា...ឆ្នាំ២០២៥ វេលាម៉ោង ..០៩:០០.........។

ការបើកសំណើដេញថ្លៃនឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមអាសយដ្ឋានខាងលើ វេលាម៉ោង..០៩:៣០....ថ្ងៃទី.....៦.......ខែ..សីហា.. ឆ្នាំ២០២៥។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់សំណើដេញថ្លៃបានតែមួយគត់។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ។

ថ្ងៃ..ពុធ ៦កើត.......ខែ..អាសាឍ..ឆ្នាំម្សាញ់ សប្តស័ក ព.ស ២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី.....១........ខែ..កក្កដា.. ឆ្នាំ២០២៥

**ជ.ប្រធានគណៈកម្មាធិការលទ្ធកម្ម**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**អនុប្រធានទី១**

**គីម សុន**

**ចម្លងជូន៖**

- អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
- អង្គភាពប្រឆាំងអំពើពុករលួយ
- ឯកសារ កាលប្បវត្តិ